# សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម

## ត្រូវការជ្រើសរើសគ្រូបង្រៀនបន្ថែម
## សម្រាប់ឆ្នាំសិក្សា២០២២ -២០២៣

ដោយមានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ព្រមទាំងដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដែលបានជួយឧបត្ថម្ភធនធានបច្ចេកទេស និងហិរញ្ញវត្ថុ **វិទ្យាល័យ ហ៊ុន សែន កំពង់ចាម** មានការអភិវឌ្ឍយ៉ាងឆាប់រហ័សទាំងបរមាណ និងគុណភាព។

**វិទ្យាល័យ ហ៊ុន សែន កំពង់ចាម** បានក្លាយជាសាលារៀនជំនាន់ថ្មីគំរូដំបូងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបរិស្ថានសិក្សាទំនើប អភិបាលកិច្ចល្អ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនខ្ពស់ ទទួលបានការទុកចិត្ត កោតសរសើរពីមាតាបិតា សិស្សានុសិស្ស សហគមន៍ និងមន្ត្រីអប់រំ និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។

សម្រាប់ឆ្នាំសិក្សាថ្មី២០២២-២០២៣ ខាងមុខនេះ វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ត្រូវការជ្រើសរើសគ្រូបង្រៀនបន្ថែមបំពេញសេចក្តីត្រូវការសាលាដូចខាងក្រោម៖

**១. គ្រូបង្រៀនកម្រិតឧត្តមចំនួន៤រូប៖**

- **ឯកទេសគណិតវិទ្យាចំនួន ០១ រូប**
- **ឯកទេសរូបវិទ្យាចំនួន ០១រូប**
- **ឯកទេសគីមីវិទ្យាចំនួន ០១រូប**
- **និងឯកទេស ជីវវិទ្យា ០១រូប ។**

**២. គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន១រូប៖**

- **ឯកទេសគណិតវិទ្យា រូបវិទ្យា ចំនួន ០១ រូប**

**លក្ខណៈសម្បត្តិ៖**

- ជាគ្រូបង្រៀនក្នុងក្របខ័ណ្ឌរដ្ឋដែលកំពុងបម្រើការក្នុងគ្រឹះស្ថានសិក្សារដ្ឋ។
- ជាគ្រូបង្រៀនទើបនឹងបញ្ចប់វគ្គបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ(គ្រូបង្រៀនកម្រិតឧត្តម) ឬបញ្ចប់វគ្គបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យភូមិភាគ (គ្រូបង្រៀនកម្រិតមូលដ្ឋាន)
- មានឆន្ទៈមោះមុតក្នុងការបំពេញការងារបង្រៀនស្របតាមកម្មវិធីកំណែទម្រង់វិស័យអប់រំ ពិសេសកម្មវិធីសាលារៀនជំនាន់ថ្មី។
- មានចំណេះដឹងជ្រៅជ្រះលើមុខវិជ្ជាឯកទេស និងគរុកោសល្យ។

- មានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងការស្រាវជ្រាវទំនើប។
- មានសុខភាពរឹងមាំ ប្រកបដោយសក្ដានុពលការងារ។

**ឱកាស និងអត្ថប្រយោជន៍៖**

- ទទួលបានកុំព្យូទ័រយួរដៃមួយគ្រឿងសម្រាប់បំពេញការងារប្រចាំថ្ងៃ។
- ទទួលបានការបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់បច្ចេកវិទ្យាICTក្នុងវិស័យអប់រំ ការបំប៉នភាសាអង់គ្លេស វិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីពង្រឹងគន្លងអាជីពគ្រូបង្រៀន
- ពង្រឹងសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឆ្លើយតបនឹងសមាហរណកម្មអាស៊ាន និងតម្រូវការអប់រំស្របនឹងនិន្នាការសាកលភាវូបនីយកម្មក្នុងសតវត្សទី២១
- ទទួលបានថវិកាលើកទឹកចិត្តតាមការបំពេញភារកិច្ចប្រចាំខែប្រមាណចាប់ពី៦០០០០០រៀល (លើកលែងវិស្សមកាល) បន្ថែមលើប្រាក់បៀវត្សផ្ដល់ដោយរាជរដ្ឋាភិបាល និងប្រាក់ឧបត្ថម្ភផ្សេងទៀតអាស្រ័យលើទំហំការងារបន្ថែម។
- ទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា។
- ចូលរួមកម្មវិធីទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស។

**លក្ខខណ្ឌ៖**

- គ្រូបង្រៀនដែលបានជ្រើសរើសមិនអនុញ្ញាតឲ្យរកកម្រៃពីសិស្សដូចជាការលក់ដូរនំចំណីក្រដាសប្រឡង ឯកសារមេរៀន និងការបង្រៀនគួងកជន
- ត្រូវបំពេញការងារបង្រៀនឲ្យបានយ៉ាងហោចណាស់គ្រប់ម៉ោងកំណត់របស់ក្រសួង។
- ទទួលការវាយតម្លៃប្រចាំឆ្នាំដោយក្រុមប្រឹក្សាភិបាលលើការបំពេញភារកិច្ច
- ក្រុមប្រឹក្សាភិបាលនឹងធ្វើការជ្រើសរើសដោយផ្អែកលើសមត្ថភាព

  បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមយកប្រវត្តិរូបសង្ខេប(CV)មកដាក់នៅទីចាត់ការ **វិទ្យាល័យ ហ៊ុន សែន កំពង់ចាម** រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃ១៥ ខែកញ្ញា ឆ្នាំ២០២២។

  សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក៖

  **១. លោក សឿង វ៉ាន់ ៖ នាយកវិទ្យាល័យ ហ៊ុន សែន កំពង់ចាម**

  *ទូរស័ព្ទ* **០៩៧ ៩៧ ០០ ២២៤ /០១០ ២៩០ ២២៤**

  Email: soeungvann@gmail.com

  **២.លោកស្រី លន់ សូម៉ានី ៖ អនុប្រធានក្រុមប្រឹក្សាភិបាល**

  *លេខទូរស័ព្ទ* **០១២ ៤៨ ៥១ ០១**